# ហេតុអ្វីមានមនុស្សជាតិ

ដំបូងក្នុងឱកាសពេលចូលឆ្នាំថ្មីប្រទេសចិនជូនពរអ្នករាល់គ្នា!

ឆ្នាំថ្មីដើមមកគួរនិយាយពាក្យសួស្តីឆ្នាំថ្មីប៉ុន្មានប្រយោគដែលអ្នករាល់គ្នាចូលចិត្តស្តាប់, ប៉ុន្តែខ្ញុំមើលឃើញគ្រោះថ្នាក់មួយជំហានៗកំពុងខិតជិតមនុស្សជាតិ។ ដោយហេតុនេះបណ្តាអាទិទេព, ព្រះពុទ្ធតម្រូវឲ្យខ្ញុំនិយាយប៉ុន្មានប្រយោគដែលអាទិទេពចង់និយាយ, ប្រយោគណាក៏ជាអាថ៌កំបាំងធម្មជាតិ, គឺដើម្បីទុកឲ្យមនុស្សដឹងអំពីសេចក្តីពិត, ម្តងទៀតផ្តល់ឱកាសបានសង្គ្រោះឲ្យមនុស្ស។

ហេតុអ្វីមានមនុស្សជាតិ, ចក្រវាលចាប់ពីបង្កើតរហូតដល់ចុងបញ្ចប់ត្រូវឆ្លងកាត់ដំណើរការបួនដំណាក់កាលកកើត, នឹងថេរ, អន់ថយ, វិនាសឃីតនិងយូរ។ ចក្រវាលកាលណាដល់ចុងបញ្ចប់នៃដំណើរការបំផ្លាញទីបញ្ចប់, ទាំងអស់ក្នុងរាងកាយលោកធាតុ, រួមបញ្ចូលទាំងចក្រវាលដែលពួកយើងរស់រានគឺនឹងរុះរើគ្មាននៅក្នុងមួយសន្ទុះ! ជីវិតទាំងអស់{ត្រូវ}បំផ្លាញទាំងមូល។

មនុស្សស្លាប់{គឺ}គ្រាន់តែជារាងកាយលើផ្ទៃពុករលួយចាស់ទៅ, ហើយវិញ្ញាណដើមរបស់មនុស្ស(ខ្លួនឯងពិតប្រាកដគ្មានស្លាប់បាត់)នឹងចាប់កំណើតឡើងវិញនៅក្នុងជាតិក្រោយ។ ចក្រវាលមានកកើត, នឹងថេរ, អន់ថយ, វិនាស, មនុស្សមានកើត, ចាស់, ឈឺ, ស្លាប់, នេះជាច្បាប់របស់ចក្រវាល, អាទិទេពក៏មានដំណើរការនេះ, គ្រាន់តែជាឃីតនិងយូរ, អាទិទេពកាន់តែធំនឹងកាន់តែឃីតនិងយូរ។ កើតស្លាប់របស់គាត់មិនមានទុក្ខឈឺចាប់, ថែមទៀតដំណើរការសុទ្ធតែដឹងច្បាស់, គឺដូចជាផ្លាស់អាវក្រៅ។ ក៏មានន័យថាជីវិតក្រោមកាលៈទេសៈធម្មតានឹងមិនស្លាប់បាត់។ ប្រសិនចក្រវាល, រាងកាយលោកធាតុនៅដំណាក់កាលទីបញ្ចប់នៃ

កកើត, នឹងចេរ, អន់ថយ, វិនាសរុះរើអស់, ជីវិតក៏មិនស្ថិតនៅចាប់កំណើតឡើងវិញ, ជីវិតនិងវត្ថុទាំងអស់គ្មាននៅទៀត, ប្រែទៅជាផេះ, ទាំងអស់វិលមកជាទទេ។ បច្ចុប្បន្នលោកីយ៍នៃមនុស្សគាប់ជួនកំពុងឆ្លងដំណើរការទីបញ្ចប់នៃវិនាសក្នុងកកើត, នឹងចេរ, អន់ថយ, វិនាស។ ទាំងអស់នៃចុងបញ្ចប់សុទ្ធតែនឹងប្រែទៅជាមិនល្អ, ដូច្នេះទើបវិនាស, ហេតុនេះសង្គមបច្ចុប្បន្នទើបនឹងចលាចលយ៉ាងនេះ។ មនុស្សគ្មានគំនិតករុណា, គំនិតច្របូកច្របល់, ចិត្តសាស្ត្របែកប្លែក, ផលិតផលពុលគ្រប់កន្លែង, មិនជឿអាទិទេព។ល។ បាតុភូតច្របូកច្របល់កើតឡើងពាសពេញ, នេះជាការចៀសមិនរួចចុងបញ្ចប់នៃរាងកាយលោកធាតុ, ជាក់ស្ដែងគឺដល់ពេលវេលានេះរួចហើយ។

ម្ចាស់បង្កើតលោកឲ្យតម្លៃក្រៃលែងជីវិតរបស់អាទិទេពជាមួយជីវិតសប្បុរសស្អាតល្អដ៏ច្រើននិងធម្មជាតិស្អាតល្អទាំងនោះក្នុងចក្រវាល, ហេតុនេះនៅសម័យដើមនៃអន់ថយ, បាននាំតាមអាទិទេពមួយចំនួនមកដល់ជាន់ក្រៅបំផុតរបស់រាងកាយលោកធាតុ(ហៅរួមថាក្រៅភពធម៌) កន្លែងដែលគ្មានអាទិទេព, បានបង្កផែនដី។ ផែនដីគ្មានវិធីស្ថិតនៅដោយឯករាជ្យ, ចាំបាច់មានរចនាសម្ព័ន្ធរាងកាយលោកធាតុដែលត្រូវគ្នាដើម្បីបង្កើតជាប្រព័ន្ធវដ្ដនៃជីវិតនិងជីវវិទ្យាទើបអាចស្ថិតនៅបាន។ ដោយហេតុនេះ, ម្ចាស់បង្កើតលោកបានបង្កវិសាលភាពធំមួយនៅក្រៅផែនដី, បណ្ដាអាទិទេពហៅថាត្រៃភព។ មិនដល់ពេលវេលាសង្គ្រោះប្រោសចុងបញ្ចប់, មិនថាអាទិទេពខ្ពស់ដល់ណា, {បើ}គ្មានការយល់ព្រមរបស់ម្ចាស់បង្កើតលោក, មិនបានតាមអំពើចិត្តចេញចូលត្រៃភព។ ក្នុងវិសាលភាពត្រៃភពមាន៣ភពធំ, សត្វលោកលើដីរួមបញ្ចូលមនុស្សជាតិជាន់នេះហៅថា"ភពតណ្ហា"; នៅលើភពតណ្ហាគឺភពទី២ជាភពរូប; ឡើងមួយជាន់ទៀតគឺជាន់ទី៣ជាភពគ្មានរូប។ ភពមួយខ្ពស់ជាងភពមួយគឺស្អាតល្អ

ជាង, តែសុទ្ធតែគ្មានវិធីផ្ទៀបនឹងឋានសួគ៌នៃភពធម៌និងលើភពធម៌។ មេឃដែលមនុស្សជាតិធម្មតានិយាយដល់, ភាពពិតគឺជាមេឃនៃភពរូបនិងភពគ្មានរូបខាងក្នុងត្រៃភព។ ហេតុអ្វីភពនីមួយៗសុទ្ធតែមានមេឃ១០ជាន់, ខាងក្នុងត្រៃភពសរុបមានមេឃ៣៣ជាន់បូកត្រៃភពខ្លួនវា។ មនុស្សនៅភពតណ្ហា, នេះជាជាន់ទាបបំផុត, បរិយាកាសក៏កំណាចអាក្រក់បំផុត។ ជីវិតមនុស្សទុក្ខនិងខ្លី, គួរឲ្យខ្លាចបំផុតគឺមនុស្សលោកីយ៍គ្មានគោលសីលធម៌សុចរិត, នៅក្នុងចក្រវាលគោលសីលធម៌នៃមនុស្សគឺបញ្ច្រាស(លើកលែងតែគោលសីលធម៌អាទិទេពសម្តែងឲ្យមនុស្ស)។ ដូចជា៖ អ្នកឈ្នះធ្វើស្តេច, សង្គ្រាមលើលោក, អ្នកខ្លាំងជាអ្នកក្លាហាន។ល។ នៅក្នុងភ្នែកអាទិទេពសុទ្ធតែមិនមែនជាគោលសីលធម៌សុចរិត, សុទ្ធតែជាសម្លាប់ប្លន់ហើយបាន។ ចក្រវាលជាមួយអាទិទេពនឹងមិនបែបនេះ, តែផ្ទុយមកវិញនៅទីមនុស្សនេះគឺចាំបាច់, គឺអាចធ្វើ, នេះជាគោលសីលធម៌នៃភពមនុស្ស, ផ្ទៀបនឹងគោលសីលធម៌នៃចក្រវាលគឺបញ្ច្រាស, ដូច្នេះចង់ត្រឡប់ទៅមេឃគឺត្រូវតែយោងតាមគោលសីលធម៌សុចរិត ដើម្បីបួសទើបបាន។ មនុស្សខ្លះរស់ល្អជាងអ្នកដទៃបន្តិច, គឺមានអារម្មណ៍ថាដ៏ល្អ, នោះជាមនុស្សប្រៀបផ្ទៀបរវាងមនុស្សនិងមនុស្សនៅភពនេះ, ភាពពិតសុទ្ធតែកំពុងរស់នៅក្នុងគំនរសំរាមនៃចក្រវាល។ ត្រៃភពកសាងនៅជាន់ក្រៅបំផុតនៃរាងកាយលោកធាតុចក្រវាល, ទីនេះគឺជាភាគល្អិតម៉ូលេគុល, អាតូម។ល។ ទាបបំផុត, គ្រើមបំផុត, ប្រឡាក់បំផុតផ្សំឡើង។ នៅក្នុងភ្នែកអាទិទេព, នេះជាក់ស្តែងជាកន្លែងចោលសំរាមរបស់ចក្រវាល។ ដោយហេតុនេះអាទិទេពចាត់ទុកជាន់ភាគល្អិតម៉ូលេគុលនេះជាភក់, ជាកន្លែងនៃជាន់ទាបបំផុត, នេះក៏ជាអត្ថន័យដើមនៃប្រការធ្លាប់និយាយក្នុងសាសនាថាព្រះជាម្ចាស់ប្រើភក់បង្កមនុស្ស, ភាពពិតគឺប្រើសារធាតុនៃជាន់ម៉ូលេគុលផ្សំឡើងបង្កមនុស្ស។

បណ្ដាអាទិទេពបង្កមនុស្សជាការចាត់តាំងរបស់ម្ចាស់បង្កើតលោក, ហៅអាទិទេពខុសគ្នាយោងតាមរូបរាងខ្លួនឯងបង្កមនុស្ស{មាន}រូបសម្បុរខុសគ្នា, ដូច្នេះមានប្រភេទមនុស្សស្បែកស, ប្រភេទមនុស្សស្បែកលឿង, ប្រភេទមនុស្សស្បែកខ្មៅនិងប្រភេទជាតិសាសន៍ដទៃទៀត, នេះគ្រាន់តែជារូបខាងក្រៅខុសគ្នា, ជីវិតខាងក្នុងគឺម្ចាស់បង្កើតលោកផ្តល់ឲ្យ, ដូច្នេះសុទ្ធតែមានគុណតម្លៃដូចគ្នា។ គោលបំណងម្ចាស់បង្កើតលោកហៅអាទិទេពបង្កមនុស្សគឺប្រើពេលចុងបញ្ចប់សង្គ្រោះប្រោសសត្វលោករាងកាយលោកធាតុចក្រវាលរួមបញ្ចូលបណ្តាអាទិទេព។

ដូច្នោះហេតុអ្វីម្ចាស់បង្កើតលោកត្រូវតែហៅបណ្ដាអាទិទេពបង្កមនុស្សជាតិនៅបរិយាកាសទាបអាក្រក់យ៉ាងនេះហ្ន៎? ដោយសារទីនេះគឺជាជាន់ទាបបំផុតរបស់ចក្រវាល, ជាកន្លែងទុក្ខបំផុត, ទុក្ខទើបអាចបួសហាត់, ទុក្ខទើបអាចរំលាយទោសកម្ម។ នៅក្នុងទុក្ខមនុស្សនៅតែអាចរក្សាសេចក្តីសប្បុរស, នៅតែចេះដឹងគុណ, ធ្វើមនុស្សល្អម្នាក់, នេះជាក់ស្តែងគឺកំពុងលើកកម្ពស់ខ្លួនឯង។ លើសពីនេះសង្គ្រោះប្រោសជាដំណើរការពីក្រោមឡើងលើ, ចាំបាច់ចាប់ផ្តើមពីកន្លែងទាបបំផុត។ ជីវិតនៅទីនេះរស់{ត្រូវតែ}ទុក្ខ, រវាងមនុស្សនិងមនុស្សនឹងមានជម្លោះផលប្រយោជន៍, បរិយាកាសធម្មជាតិ{ត្រូវតែ}កំណាចអាក្រក់, ដើម្បីរស់រានមនុស្សនឹងត្រូវហាត់ចិត្តហាត់កម្លាំង។ល។និង។ល។ សុទ្ធតែអាចផ្តត់ផ្គង់ឲ្យជីវិតឱកាសដើម្បីលើកកម្ពស់, រំលាយកម្ម។ ទុក្ខអាចរំលាយទោសកម្មគឺជាប្រាកដ, ក្នុងទុក្ខឈឺចាប់និងទំនាស់, មនុស្សនៅតែរក្សាសេចក្តីសប្បុរសគឺនឹងសន្សំកុសលគុណធម៌, ហេតុនេះជីវិតសម្រេចបានលើកថ្កើង។

ពេលដល់សម័យទំនើបម្ចាស់បង្កើតលោកត្រូវការប្រើរាងកាយមនុស្សដើម្បីសង្គ្រោះប្រោសសត្វលោកចក្រវាល, ជីវិតដើមមានក្នុងរាង

កាយមនុស្សភាគច្រើនត្រូវបានអាទិទេពចាប់កំណើតឡើងវិញធ្វើមនុស្ស ជំនួស។ ដោយសាររាងកាយមនុស្សអាចនៅក្នុងទុក្ខដើម្បីរំលាយទោសកម្ម, ក្នុងពេលដំណាលគ្នានៅក្នុងគ្មានគោលសីលធម៌សុចរិត, អាចរក្សារឹងមាំគោលសីលធម៌សុចរិតដែលអាទិទេពនិយាយ, ក៏អាចរក្សាសេចក្តីសប្បុរសគឺនឹងសម្រេចបានលើកកម្ពស់របស់ជីវិត។ ចុងបញ្ចប់បានដល់រួចហើយ, ទ្វារមេឃត្រៃភពបានបើករួចហើយ, ម្ចាស់បង្កើតលោកបាននិងកំពុងជ្រើសរើសប្រភេទមនុស្សនេះដើម្បីសង្គ្រោះប្រោស។

រាងកាយលោកធាតុចក្រវាលនៅក្នុងដំណើរការកកើត-នឹងថេរ-អន់ថយទាំងអស់សុទ្ធតែមិនបរិសុទ្ធទៀត, សុទ្ធតែមិនល្អដូចពេលកកើតដំបូងទៀត, ទើបនឹងដើរដល់វិនាស។ ក៏មានន័យថាទាំងអស់នៅក្នុងរាងកាយលោកធាតុសុទ្ធតែអន់ថយ, សត្វលោកសុទ្ធតែមិនល្អដូចពេលចាប់ផ្តើមដំបូងយ៉ាងនោះទៀត, ជីវិតក៏សុទ្ធតែមិនបរិសុទ្ធទៀត, សុទ្ធតែមានទោសកម្ម, ដូច្នេះទើបនឹងវិនាស។ ក្នុងសាសនាហៅប្រភេទទោសនេះថាអំពើបាបដំបូង។ ដើម្បីសង្គ្រោះទុករាងកាយលោកធាតុចក្រវាល, ម្ចាស់បង្កើតលោកហៅបណ្តាអាទិទេព, បណ្តាម្ចាស់ចុះលោកីយ៍នៅក្នុងបរិយាកាសនេះធ្វើមនុស្ស, រងទុក្ខ, លើកកម្ពស់, រំលាយទោស, កែប្រែខ្លួនឯងឡើងវិញ, ហេតុនេះត្រឡប់ទៅឋានសួគ៌វិញ។ (ព្រោះម្ចាស់បង្កើតលោកសង្គ្រោះមនុស្សក្នុងពេលដំណាលគ្នាក៏កំពុងបង្កចក្រវាលសាជាថ្មី)រាងកាយលោកធាតុចក្រវាលថ្មីគឺបរិសុទ្ធល្អស្អាតដាច់ខាត, នៅក្នុងបរិយាកាសទុក្ខលំបាកមនុស្សអាចរក្សាគំនិតករុណា, ប្រឈមមុខនឹងផលប៉ះពាល់នៃគោលគំនិតទំនើប, មនុស្សអាចរក្សារឹងមាំគោលគំនិតប្រពៃណី, នៅក្នុងផលប៉ះពាល់នៃទ្រឹស្តីមិនជឿព្រះ, ទ្រឹស្តីនៃការវិវត្តន៍, នៅតែអាចជំនឿអាទិទេព, មនុស្សបែបនេះជាក់ស្តែងគឺសម្រេចបានគោលបំណងត្រូវបានសង្គ្រោះត្រឡប់ទៅឋានសួគ៌។ ភាពរីករាយទាំងអស់

សុទ្ធតែជាអាទិទេពរៀបចំនៅទីបញ្ចប់, គោលបំណងគឺដើម្បីសាកល្បងសត្វលោកអាចបានសង្គ្រោះប្រោសឬអត់, ក្នុងពេលដំណាលគ្នាទុក្ខក៏អាចរំលាយទោសកម្មនៅក្នុងដំណើរការនេះ, ទាំងអស់ដើម្បីប្រោសមនុស្សត្រឡប់ទៅពិភពឋានសួគ៌វិញ។

ដូច្នោះក៏មានន័យថា, ជីវិតមនុស្សនៅលោកីយ៍មិនមែនជាដើម្បីសមិទ្ធិផលអ្វីនៅសង្គម, ជីវិតមនុស្សតស៊ូ, ប្រយុទ្ធ, ឆក់ទាញមិនរើសអើងឧបាយកល, នេះគ្រាន់តែអាចធ្វើឲ្យមនុស្សប្រែជាអាក្រក់។ ចុះលោកីយ៍ធ្វើមនុស្សគឺដើម្បីរំលាយទោសកម្ម, យកបួសល្អខ្លួនឯងធ្វើជាគោលបំណង។ មនុស្សមកលោកីយ៍គឺដើម្បីបានសង្គ្រោះ, គឺដើម្បីរង់ចាំម្ចាស់បង្កើតលោកសង្គ្រោះត្រឡប់ទៅពិភពឋានសួគ៌ទើបមកធ្វើមនុស្ស, ក្នុងពេលរង់ចាំជាតិនេះជាតិផ្សេងសុទ្ធតែកំពុងសន្សំកុសលគុណធម៌, នេះក៏ជាគោលបំណងមនុស្សវិលកើតវិលស្លាប់ចាប់កំណើតឡើងវិញ, លោកីយ៍រីកវរគឺដើម្បីសមិទ្ធិផលសត្វលោក។ ទោះយ៉ាងណាក៏មានមនុស្សមួយចំនួនពេលប្រឈមនឹងលំបាកសុំអាទិទេពជួយ, គ្មានសម្រេចបានពេញចិត្តហើយចាប់ផ្ដើមកំហឹងអាទិទេព, ហេតុនេះដើរសំដៅស្ថានភាពប្រឆាំងអាទិទេព, សូម្បីតែចូលក្នុងផ្លូវរបស់ខ្មោចបង្កទោសកម្មថ្មី។ មនុស្សដូចនេះចូរឆាប់ហ័សត្រឡប់មកវិញ, សុំអាទិទេពអភ័យទោស, ត្រឡប់ក្បាលគឺច្រាំង។ ភាពពិតទាំងអស់នៃជីវិតមនុស្ស, គួរបាននិងមិនគួរបាន, សុទ្ធតែជាមួយជីវិតមុន, មួយជាតិមុនធ្វើល្អនិងធ្វើមិនល្អបានបង្កជាហេតុផលនៃមួយជីវិតក្រោយ, មួយជាតិក្រោយ, មួយជាតិមុនសន្សំបានលាភគុណធម៌ប៉ុន្មានហើយកំណត់ជាតិនេះឬក៏ជាតិក្រោយចំណែកលាភបានប៉ុណ្ណោះ។ លាភគុណធម៌ច្រើន, ជាតិក្រោយគឺអាចប្រើលាភគុណធម៌ប្ដូរមកមន្ត្រីខ្ពស់ប្រាក់ខែក្រាស់, ក៏អាចប្ដូរមកលុយទ្រព្យចំណែកលាភគ្រប់ប្រភេទ។ល។ រួមបញ្ចូលគ្រួសារគឺសុភ

មង្គលឬអត់, សូម្បីតែកូនចៅយ៉ាងណា។ នេះជាក់ស្តែងគឺជាមូលហេតុគ្រឹះមានអ្នកមាន, មានអ្នកក្រ, មានមនុស្សធ្វើមន្ត្រីធំ, មានមនុស្សគ្មានផ្ទះដើម្បីមក, មិនមែនជាសំណុំពាក្យសម្តីខ្មោចព្រាយតុល្យភាពអ្នកមានអ្នកក្រដូចដែលបក្សកុម្មុយនីស្តទុច្ចរិតបានឃោសនានោះ។ ចក្រវាលគឺយុត្តិធម៌, ជីវិតធ្វើល្អនឹងមានលាភរង្វាន់, ធ្វើរឿងអាក្រក់នឹងត្រូវការសង, ជីវិតនេះមិនសងជីវិតក្រោយសង, នេះជាច្បាប់ធម៌ដាច់ខាតរបស់ចក្រវាល! មេឃ, ដី, អាទិទេព, ម្ចាស់បង្កើតលោកចំពោះសត្វលោកគឺមេត្តា, មេឃ, ដី, មនុស្ស, អាទិទេពសុទ្ធតែជាម្ចាស់បង្កើតលោកបង្ក, ដាច់ខាតមិនប្រព្រឹត្តល្អសម្រាប់មួយចំនួនជីវិតណាមួយ, ប្រព្រឹត្តមិនល្អសម្រាប់មួយចំនួនជីវិតណាមួយ។ សំណាងកម្មផល, នេះជាមូលហេតុគ្រឹះនៃជីវិតមនុស្សមានលាភនិងអត់មានលាភ។

បង្ហាញរបស់បាននឹងបាត់, នៅក្នុងតថភាពមើលទៅគឺដូចការបង្ហាញធម្មតារបស់សង្គម, ជាមូលដ្ឋានគឺជីវិតខ្លួនឯងបង្កជាហេតុមុនផលក្រោយ។ ប៉ុន្តែមាននិងគ្មាន, បាននិងបាត់, នៅលើបង្ហាញនៃសង្គមមនុស្សជាតិគឺស្របតាមស្ថានភាពសង្គមនៃមនុស្សជាតិ, ដូច្នេះជីវិតមនុស្សនៅលោកីយ៍មិនថាជីវិតលោកអ្នកមានឬក្រ, ជាក់លាក់ត្រូវធ្វើរឿងល្អ, មិនធ្វើរឿងអាក្រក់, រក្សាសេចក្តីសប្បុរស, គោរពមេឃគោរពអាទិទេព, រីករាយជួយមនុស្ស, ជាតិក្រោយគឺនឹងទទួលបានលាភរង្វាន់។ បែបនេះគឺនឹងសន្សំបានលាភគុណធម៌។ កាលពីមុនមនុស្សចាស់នៅប្រទេសចិនតែងតែនិយាយៈ ជាតិនេះទុក្ខបន្តិចមិនបានអន់ចិត្តមេឃអន់ចិត្តដី, ធ្វើរឿងល្អបានច្រើនសន្សំគុណធម៌បានច្រើន, ជាតិក្រោយនឹងល្អ, ក៏មានន័យថាមួយឆាកជីវិតមុនមិនធ្វើរឿងល្អ, មិនសន្សំលាភគុណធម៌, លោកអ្នកសុំអាទិទេពមកជួយក៏គ្មានប្រយោជន៍។ ចក្រវាលមានច្បាប់ធម៌នៃចក្រវាល, អាទិទេពក៏ត្រូវតែធ្វើតាម។ អាទិទេពបានធ្វើអ្វីមិន

គួរធ្វើ, អាទិទេពក៏នឹងទទួលទោសផងដែរ។ មិនសាមញ្ញដូចមនុស្សគិតនោះទេ, អ្វីដែលលោកអ្នកចង់បានអាទិទេពនឹងធ្វើឲ្យលោកអ្នក? លក្ខខណ្ឌគឺថាលោកអ្នកចាំបាច់មានលាភគុណធម៌សន្សំពីជាតិមុន, ប្រើលាភគុណធម៌ដើម្បីប្ដូរយក! ដោយសារនេះជាច្បាប់ធម៌នៃចក្រវាលបានកំណត់។ ប៉ុន្តែនិយាយជាមូលដ្ឋាន, នេះមិនមែនជាគោលបំណងមូលដ្ឋាននៃការសន្សំលាភគុណធម៌។ ជីវិតមនុស្សនៅលោកីយ៍សន្សំលាភគុណធម៌បានច្រើន, ដើម្បីសន្សំគ្រួសត្រាយផ្លូវខ្លួនឯងសម្រាប់ត្រឡប់ទៅមេឃវិញទើបជាគន្លឹះបំផុត, ហើយមិនមែនជាដើម្បីប្ដូរយកសុភមង្គលមួយពេលមួយជាតិរបស់ជីវិតមនុស្ស។

លោកគ្រូ៖ លីហុងជឺ
ថ្ងៃទី១៤រោច ខែមិគសិរ ឆ្នាំខាលចត្វាស័ក
ថ្ងៃទី២០ ខែមករា ឆ្នាំ២០២៣

********

**ចំណាំ៖** (*ចំណាំគឺជារបស់អ្នកបកប្រែចិន-ខ្មែរ, គ្រាន់តែទុកជាឯកសារយោង*)

បកប្រែពីភាសាដើមចិន៖
https://www.minghui.org/mh/articles/2023/1/20/455562
មានពិគ្រោះការបកប្រែជាភាសាអង់គ្លេស៖
https://en.minghui.org/html/articles/2023/1/21/206699.html

បកប្រែថ្ងៃទី២៤-១០-២០២៣, កែសម្រួលថ្ងៃទី១០-០៥-២០២៤, អត្ថបទបកប្រែនេះអាចនឹងកែសម្រួលនាពេលអនាគតដើម្បីឱ្យអត្ថន័យបកប្រែជាភាសាខ្មែរកាន់តែខិតជិតអត្ថន័យដើមនៃភាសាចិនបំផុត។

<u>ពន្យល់ពាក្យ៖</u>

**ទោសដើម ឬ អំពើបាបដំបូង៖** ក្នុងគ្រិស្តសាសនា, "original sin" បានបកប្រែថាទោសដើមឬអំពើបាបដំបូង(ទោសដើមដំបូង)។

**ទ្រឹស្តីមិនជឿព្រះ៖** (Atheism)មិនជឿថាមានអាទិទេពព្រះពុទ្ធស្ថិតនៅ។

**ទ្រឹស្តីនៃការវិវត្តន៍៖** ទ្រឹស្តីនៃការវិវត្តន៍មិនជឿថាអាទិទេពបានបង្កចេញមនុស្ស។